ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៩៣៤ មស.សស

# សេចក្តីសម្រេច
# ស្តីពី
# ការអនុញ្ញាតឱ្យបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលចូលរួមប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០១៧

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ ៤៧៨មស.ក្រខ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ១២៩៦ ពណ.បល ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិតលេខ០៤៤៨ បទ.បប ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងលិខិតលេខ១២៤២ ធទឧ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងធនធានទឹកនិងឧតុនិយម
- យោងលិខិតលេខ៥២៤៥ កសក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- យោងលិខិតលេខ៩៥៥ លស.អរហ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ០៥៥៧ លេអស ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

# សម្រេច

**ប្រការ ១ ៖** ត្រូវបានអនុញ្ញាតឱ្យបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ចំនួន **៥១៩៣នាក់** ចូលរួមប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម៖



ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh